# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## អំពីវត្តនិងព្រះសង្ឃព្រះពុទ្ធសាសនាខ្មែរ

**web site: hoksavann.org**

ថ្ងៃទី២៨ មីនា ២០០៦

ពាក្យថាវត្តជាភាសាខ្មែរ ដែលចេញមកពីភាសាបាលីថា វត្តំ ប្រែថាទីកន្លែងសំរាប់គោរពបូជា ជាកន្លែងសំរាប់ព្រះសង្ឃរស់នៅ ។ សេចក្ដីថា ព្រះសង្ឃពុំអាចរស់នៅ ជាមួយគ្រហស្ថបានទេ គឺត្រូវរស់នៅកន្លែងមួយដាច់ដោយឡែក ដែលហៅថាវត្តនេះឯង ។ ក្នុងភាសាបាលីមានប្រើពាក្យមួយទៀតថា អារាម ប្រែថាជាទីរីករាយចិត្ត គឺបើគេមានទុក្ខកង្វល់ផ្លូវចិត្ត ពេលណាគេចូលវត្តបានទាញអារម្មណ៍គេ ឲ្យរីករាយផ្លូវចិត្តក្នុងភាពស្ងប់ ព្រោះវត្តជាទីរម្ងាប់នូវអំពើបាប និងការកង្វល់ផ្លូវចិត្ត ។ ក្រៅពីព្រះសង្ឃ វត្តមានវត្ថុជាទីគោរពសក្ការៈ ដូចជាព្រះវិហារ ព្រះពុទ្ធរូប គម្ពីរព្រះត្រៃបិដកជាដើម ។ គេសង្កេតឃើញនៅប្រទេសកម្ពុជា បើមានភូមិនៅកន្លែងណា តែងតែមានវត្តព្រះពុទ្ធសាសនានៅកន្លែងនោះ និងនៅតាមទីក្រុងក៏មានដូចគ្នាដែរ ។ ពុទ្ធសាសនិកជនខ្មែរ ទុកវត្តអារាមជាទីគោរពបូជា រួមគ្នាក្នុងការបំពេញបុណ្យទាន និងការរម្ងាប់អំពើបាប ។

ពាក្យថា ព្រះសង្ឃប្រែថាក្រុមឬពួក ដែលចេញមកអំពីភាសាបាលីថាសង្ឃោ បានដល់ក្រុមឬពួករបស់បព្វជិតឬអ្នកបួស គឺភិក្ខុនិងសាមណេរ ដែលជាអ្នកលះបង់ពីភេទជាគ្រហស្ថ មកបួសក្នុងឧត្តមភេទ កាន់ព្រះពុទ្ធសាសនាមានកិរិតខ្ពស់ ព្រោះឃើញភ័យក្នុងវដ្ដសង្សារ ពីការកើតចាស់ឈឺស្លាប់ ហើយរស់នៅក្រោមធម៌វិន័យរបស់ព្រះពុទ្ធ ។ ព្រះសង្ឃព្រះពុទ្ធសាសនាមានភារកិច្ចពីរយ៉ាងគឺ សិក្សាធម៌វិន័យរបស់ព្រះពុទ្ធឲ្យបានយល់ច្បាស់ និងប្រតិបត្តិតាមឲ្យបានត្រឹមត្រូវ ។ ក្រៅពីនោះ ព្រះសង្ឃមានតួនាទីមួយទៀត គឺការយកធម៌វិន័យរបស់ព្រះពុទ្ធ មកពន្យល់ណែនាំពុទ្ធបរិស័ទ ឲ្យបានយល់ច្បាស់និងប្រតិបត្តិតាមឲ្យបានត្រឹមត្រូវដែរ ។ ដូច្នេះព្រះសង្ឃជាភេទពិសេស ជាភេទបរិសុទ្ធ អាចមានឱកាសប្រតិបត្តិធម៌សីលសមាធិបញ្ញា និងផ្សព្វផ្សាយ ព្រមទាំងរក្សាការពារព្រះពុទ្ធសាសនាបានច្រើនជាងគ្រហស្ថ ។ ព្រះស

ង្ឃស្ថិតនៅក្នុងបាវចនាទាំងបីនៃព្រះត្រៃសរណគមន៍ គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ដែលពុទ្ធបរិស័ទខ្មែរ យកជាទីពឹងទីរំលឹកស្មើដោយជីវិតរបស់ខ្លួន ដូចបាលីសូត្រនមស្សការថា នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ ធម្មោ សង្ឃោ មេ សរណំ វរំ ប្រែថា ដទៃជាទីពឹងទីរលឹកនៃខ្ញុំព្រះករុណាពុំមានឡើយ មានតែព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃជាទីពឹង ទីរំលឹកស្មើដោយជីវិតរបស់ខ្ញុំព្រះករុណា ។ ដូច្នេះព្រះសង្ឃជាទីគោរព ការប្រើពាក្យហៅព្រះសង្ឃ ក៏ឲ្យមានបានសមរម្យដែរ គឺត្រូវប្រើពាក្យថា «ព្រះសង្ឃ» កុំប្រើពាក្យថា «លោកសង្ឃ» ដូច្នេះឡើយ ព្រោះពាក្យថាលោក គេមានប្រើសំរាប់ហៅគួរសមជាមួយគ្រហស្ថ ដូចហៅឈ្មោះលោកនេះលោកនោះជាដើម ។ ការហៅដោយមិនប្រើពាក្យ«ព្រះ» នៅខាងដើម ជាពាក្យហៅខ្វះការគោរពចំពោះព្រះសង្ឃ ។ ព្រះសង្ឃជាឧត្តមភេទ មានគុណធម៌ មានសីលគុណជាដើមគួរគោរព ជាអ្នកលះបង់អំពើអាក្រក់អស់ហើយ បានដល់អរិយសង្ឃ និងព្រះសង្ឃកំពុងព្យាយាមលះបង់បានដល់សម្មតិសង្ឃ ។

វត្តអារាមព្រះពុទ្ធសាសនាខ្មែរ ពុំមែនត្រឹមតែជាមជ្ឈមណ្ឌល សំរាប់គោរពប្រតិបត្តិព្រះពុទ្ធសាសនាប៉ុណ្ណោះទេ លើសអំពីនេះទៀត ជាមជ្ឈមណ្ឌលសំរាប់ទុកនិងបណ្តុះបណ្តាល នូវវប្បធម៌ អក្សរសាស្ត្រ ប្រវត្តិសាស្ត្រ ប្រពៃណីទំនៀមទំលាប់គ្រប់ផ្នែករបស់ខ្មែរ ស្ថិតនៅក្នុងវត្ត ។ ពុទ្ធបរិស័ទចំណុះជើងវត្តនីមួយៗ តែងតែស្តាប់ឱវាទព្រះសង្ឃចៅអធិការ អំពីកិច្ចការព្រះពុទ្ធសាសនា ក៏ដូចជាជីវភាពប្រចាំថ្ងៃ ដូចជាការរំលឹកដាស់តឿន ឲ្យខំប្រឹងប្រែងប្រកបការងារដោយសុចរិត ដោយមិនដេកចាំសំណាង, កុំទាស់ទែងខ្វែងគំនិតគ្នារវាងប្តីប្រពន្ធ និងអ្នកជិតខាងជាដើម ។ ប្រជាពលរដ្ឋពុទ្ធបរិស័ទខ្មែរ ទុកព្រះសង្ឃជាគ្រូរបស់ខ្លួន ដែលខ្លួនគប្បីយកឱវាទនោះមកពីចារណា ។ កូនចៅប្រុសជំទង់ខ្មែរខ្លះ ត្រូវបានម្តាយឪពុកយកទៅទុកក្នុងវត្ត ដើម្បីសុំព្រះសង្ឃជួយអប់រំខាងសីលធម៌ ហើយឲ្យបួសជាសាមណេរជាភិក្ខុ បើសឹកមកវិញ គេហៅថាអន្ទិត ដែលក្លាយមកពីពាក្យបណ្ឌិត ដែលប្រែថាអ្នកចេះដឹង ។ កូនចៅខ្មែរអ្នកស្រែចំការដែលក្រីក្រ បានមកសំណាក់នៅក្នុងវត្ត ជាពិសេសវត្តនៅទីក្រុង ដើម្បីបន្តការសិក្សានៅអនុវិទ្យាល័យ និងមហាវិទ្យាល័យរបស់រដ្ឋ ព្រោះរដ្ឋពុំបានរៀបចំឲ្យមានផ្ទះសំរាប់និស្សិតស្នាក់នៅឡើយ ។ ក្រៅពីនោះ ព្រះសង្ឃបានជួយកិច្ចការខាងសង្គមកិច្ចជាច្រើនទៀត ដូចជាធ្វើជាអ្នកដឹកនាំកសាងសាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ជាដើម ។

ពុទ្ធសាសនិកជនខ្មែរចាត់ទុកវត្តអារាមនិងព្រះសង្ឃ ជាទីកន្លែងនិងជាបុគ្គលដែលខ្លួនគប្បីគោរពបូជា ។ ដូច្នេះហើយបានជាពេលចូលវត្ត បើមានពាក់មួកតែងដោះមួក ពេលចូលព្រះវិហារ និងទីកន្លែងមានព្រះពុទ្ធរូប បើពាក់ទ្រនាប់ជើង តែងតែដោះចេញ ហើយថ្វាយបង្គំដោយសេចក្តីគោរព ។ កាលជំនាន់ដើម បើមានមនុស្សមានការភិតភ័យអំពីបញ្ហាអ្វីមួយរត់ចូលវត្ត ប៉ូលិសមិនហ៊ានចូលលុកលុយចាប់

មនុស្សក្នុងវត្តឡើយ ដោយការគោរពទីវត្ត និងគោរពព្រះសង្ឃ ព្រោះអ្នករត់ចូលវត្ត គឺរត់រកទីពឹងពីការគំរាមកំហែងបែបណាមួយពីជនឬក្រុមណាមួយ ។ ប្រៀបដូចមនុស្សរត់ទៅក្រៅប្រទេស ឬរត់ចូលស្ថានទូតណាមួយ ដើម្បីគេចពីការគំរាមកំហែងដល់ជីវិតពីរដ្ឋាភិបាលផ្តាច់ការ ដែលអង្គការសហប្រជាជាតិមានច្បាប់សំរាប់ការពារជនមានលក្ខណៈបែបនេះ ។ សម័យពុទ្ធកាល ក្នុងបិដកខ្មែរភាគ៦ក៏មាននិយាយថា ព្រះបាទពិម្ពិសារបានអនុញ្ញាតដល់ជនដែលមានទោសហើយ រត់មកបួសមិនឲ្យបុគ្គលណាមួយធ្វើទោសដល់ជននោះឡើយ ដោយព្រះរាជឱង្ការថា ជនទាំងឡាយណាដែលបួស ក្នុងសំណាក់សមណសក្យបុត្រ ជនដទៃធ្វើទោសអ្វីមួយដល់ពួកនេះមិនបានឡើយ ព្រោះថាធម៌ព្រះដ៏មានព្រះភាគទ្រង់សំដែងល្អហើយ ជននោះចូរខំប្រព្រឹត្តព្រហ្មចរិយាធម៌ ដើម្បីធ្វើនូវព្រះនិព្វានជាទីបំផុតនៃទុក្ខដោយប្រពៃចុះ ។ ត្រង់ចំណុចនេះ គួរពិចារណាព្រះវិន័យ ត្រង់បព្វជ្ជាខន្ធថា ព្រះពុទ្ធមិនអនុញ្ញាតឲ្យបុគ្គល ដែលជំពាក់បំណុលគេ បុគ្គលមានទោសបួសឡើយ ព្រោះដើម្បីកុំឲ្យមានរឿងរ៉ាវក្នុងសហគមន៍ព្រះសង្ឃ ។

ពោលដោយសង្ខេប វត្តនិងព្រះសង្ឃជាមូលដ្ឋាននៃវប្បធម៌ខ្មែរ ឬជាព្រលឹងអត្តសញ្ញាណខ្មែរ ស្ថិតនៅក្នុងចិត្តគំនិតខ្មែរជានិច្ច ដែលពុំអាចបំបែកបាន ។ ភស្តុតាង ខ្មែរក្រហមបានបំផ្លាញព្រះពុទ្ធសាសនាដល់ឫសគល់ តែវាត្រូវបរាជ័យវិនាសខ្លួនឯង ចំណែកព្រះពុទ្ធសាសនាស្ថិតនៅក្នុងចិត្តគំនិតខ្មែរដដែល ។ ឥឡូវនេះ សាសនាដទៃកំពុងវាយលុក បំផ្លាញព្រះពុទ្ធសាសនាជំនួសខ្មែរក្រហម សូមពុទ្ធសាសនិកជនខ្មែរប្រុងប្រយ័ត្ន។៚

❑ ❑

❑